**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤៦ សសរ

## សេចក្តីសំរេច
## ស្តីពី
## ការរៀបចំ «វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលមាត្រា១ នៃអនុក្រឹត្យលេខ១៤៧ អនក្រ.បក

តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ :-**

ត្រូវបានចាត់តាំងឥស្សរជនជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ដូចមានរាយនាមខាងក្រោម ជា **«គណៈដឹកនាំវេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី២»** ឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល ការត្រៀមរៀបចំ និងការដឹកនាំ **«វេទិកាលើកទី២»** នេះ ដែលគ្រោងនឹងប្រព្រឹត្ត នាថ្ងៃទី០៤-០៥ ខែធ្នូ ឆ្នាំ២០០៨ ខាងមុខនេះ ÷

- ឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជា **ប្រធានវេទិកា**
- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជា **ប្រធានបំរុងវេទិកា**
- ឯកឧត្តម **ឈៀង យ៉ានរ៉ា** អគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា អនុប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ជា **អគ្គលេខាធិការវេទិកា**

**ប្រការ ២ :-**

ក្នុងក្របខ័ណ្ឌនៃការសំរបសំរួលការត្រៀមរៀបចំនិងដឹកនាំវេទិកាលើកទី២នេះ **គណៈដឹកនាំវេទិកា** តាមរយៈ **ប្រធានវេទិកា** ត្រូវសហការជាមួយនឹងប្រធាននៃបណ្តាក្រសួង និងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ ឱ្យចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់ចែងពិគ្រោះយោបល់ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសម្របសម្រួលការងារ និងដើម្បីរៀបចំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣ :-**

**ប្រធានវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូន **សម្តេច នាយករដ្ឋមន្ត្រី** អំពីវឌ្ឍនភាពនៃការរៀបចំវេទិកាលើកទី២ និងឯកសារចាំបាច់នានា ដើម្បីដាក់ជូន **សម្តេច នាយករដ្ឋមន្ត្រី** ពិនិត្យ ផ្តល់អនុសាសន៍ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤ :-**

ក្នុងការត្រៀមរៀបចំវេទិកាលើកទី២ **អគ្គលេខាធិការវេទិកា** ត្រូវរាយការណ៍ជាបន្តបន្ទាប់ ពីវឌ្ឍនភាពការងារជូន **ប្រធានវេទិកា** និង **ប្រធានបំរុងវេទិកា** ដោយត្រូវប្រើប្រាស់រចនាសម្ព័ន្ធរបស់គណៈ-កម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**ប្រការ ៥ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងប្រធានវេទិកា ប្រធានបំរុងវេទិកា និងអគ្គលេខាធិការវេទិកា ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦ :-**

សេចក្តីសំរេចនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់វេទិកាសំរាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

- ខុទ្ទកាល័យ សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

-ដូចប្រការ៥

-ឯកសារ-កាលប្បវត្តិ